# សេចក្តីប្រកាសព័ត៌មាន
# អង្គការសង្គមស៊ីវិលជាង១០
# នឹងរៀបចំសន្និសីទរួមគ្នាដើម្បីរំលឹកទិវាសេរីភាពសារព័ត៌មានពិភពលោក
# ចំពេលមានការកើនឡើងនៃបញ្ហាប្រឈមចំពោះសេរីភាពសារព័ត៌មាននៅកម្ពុជា

**ភ្នំពេញ ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២៥** - ដោយមើលឃើញពីការធ្លាក់ចុះនៃសេរីភាពសារព័ត៌មាននៅកម្ពុជា ក្រុមអង្គការ សង្គមស៊ីវិលជាង១០ ដែលធ្វើការលើកកម្ពស់សេរីភាពសារព័ត៌មាន និងសិទ្ធិមនុស្ស នឹង រួមគ្នារៀបចំសន្និសីទរយៈពេលកន្លះថ្ងៃ ដើម្បីប្រារព្ធទិវាសេរីភាពសារព័ត៌មានពិភពលោកឆ្នាំ២០២៥ ដោយមានការចូលរួមពីអ្នកសារព័ត៌មាន អង្គការសង្គមស៊ីវិល ដៃគូអភិវឌ្ឍន៍ និងអ្នកតស៊ូមតិលើសិទ្ធិរបស់ប្រព័ន្ធផ្សព្វផ្សាយ យ៉ាងហោចណាស់១០០នាក់ ដើម្បីឆ្លុះបញ្ចាំងនូវស្ថានភាពបច្ចុប្បន្ននៃឯករាជ្យភាពប្រព័ន្ធផ្សព្វផ្សាយនៅប្រទេសកម្ពុជា។

សន្និសីទនេះនឹងប្រព្រឹត្តទៅនៅថ្ងៃទី២ ខែឧសភា ឆ្នាំ២០២៥ វេលាម៉ោង១:៣០នាទី រសៀល នៅសណ្ឋាគារ ហ៊ីម៉ាវ៉ារី ក្នុងរាជធានីភ្នំពេញ ដោយផ្តល់នូវវេទិកាសម្រាប់ការសន្ទនា ការរឹតបន្តឹងសាមគ្គីភាព និងចំណាត់ការឆ្លើយតបទៅនឹងការរឹតត្បិត មកលើប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ និងអ្នកសារព័ត៌មាន។

"ការការពារប្រព័ន្ធផ្សព្វផ្សាយឯករាជ្យនៅកម្ពុជា" គឺជាប្រធានបទនៅឆ្នាំនេះ ដែលធ្វើឡើងក្នុងគោលបំណងគូសបញ្ជាក់អំពីកំណើនសម្ពាធដែលគំរាមកំហែងដល់ការរស់រានមានជីវិតរបស់សារព័ត៌មានឯករាជ្យ ក៏ដូចជាតួនាទីដ៏សំខាន់របស់ពួកគេក្នុងការជូនដំណឹងដល់សាធារណជន និងអំពីរបៀបនៃការឆ្លើយតបចំពោះការគំរាមកំហែងផ្នែកសុវត្ថិភាព និង វិបត្តិថ្មីៗដែលបណ្តាលមកពីការកាត់ផ្តាច់ជំនួយរបស់សហរដ្ឋអាមេរិក។

ព្រឹត្តិការណ៍នេះ ក៏មានគោលបំណងជំរុញកិច្ចសន្ទនាអំពីយុទ្ធសាស្ត្រ ដើម្បីការពារអ្នកសារព័ត៌មានស៊ើបអង្កេត និងលំហដែលនៅសេសសល់សម្រាប់ប្រព័ន្ធផ្សព្វផ្សាយឯករាជ្យនៅក្នុងប្រទេស។

សន្និសីទនេះនឹងមានការថ្លែងសុន្ទរកថាគន្លឹះ កិច្ចពិភាក្សា និងសម្តែងនូវការគោរពនិងកោតសរសើរចំពោះវីរភាពរបស់អ្នកសារព័ត៌មាននៅកម្ពុជា និងជុំវិញពិភពលោក ដែលបន្តរាយការណ៍ព័ត៌មានបាន ទោះបីជាត្រូវប្រឈមមុខនឹងការត្រួតពិនិត្យ ការបំភិតបំភ័យ និងអំពើហិង្សាក៏ដោយ។

លោក ណុប វី នាយកប្រតិបត្តិ នៃសមាគមសម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា (ខេមបូចា) បានឲ្យដឹងថា៖ «សារព័ត៌មានឯករាជ្យគឺជាវិជ្ជបណ្ឌិត ដែលធ្វើការវិភាគវិជ្ជសាស្ត្រដើម្បីប្រាប់ពីការពិតនៃបញ្ហារបស់សង្គម ដើម្បីឲ្យមានការឆ្លើយតបនឹងដោះស្រាយ។ បើខ្វះតួនាទីរបស់សារព័ត៌មានឯករាជ្យ បញ្ហារបស់សង្គមនឹងមិនត្រូវបានដោះស្រាយ ហើយរដ្ឋាភិបាលក៏នឹងមិនទទួលបានការជឿទុកចិត្តពីពលរដ្ឋទាំងអស់នៅក្នុងសង្គមដែរ»។

**តំណាងមកពីស្ថាប័នប្រព័ន្ធផ្សព្វផ្សាយនានាត្រូវបានស្វាគមន៍ក្នុងការចូលរួមព្រឹត្តិការណ៍នេះ។**
**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖**

- លោកលោក ណុប វី  នាយកប្រតិបត្តិ នៃសមាគមសម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា (ខេមបូចា)
  អ៊ីមែល៖ ed@camboja.net
- លោក ស៊ន សារ៉ាត  មន្ត្រីគ្រប់គ្រងកម្មវិធីស្រាវជ្រាវ និងតស៊ូមតិ នៃសមាគមសម្ព័ន្ធអ្នកព័ត៌មានកម្ពុជា (ខេមបូចា)
  អ៊ីមែល៖ sarath.sorn@camboja.net